# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៩៧,១០០ ដុល្លារអាមេរិក សម្រាប់ការកសាងអគារព្យាបាលជំងឺទូទៅ

តាមរយៈកម្មវិធីគម្រោងជំនួយឥតសំណង សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណេ*) រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយដែលមានទឹកប្រាក់សរុបចំនួន ៩៧,១០០ ដុល្លារអាមេរិកដល់ស្រុកប្រតិបត្តិពារាំងសម្រាប់គម្រោងសាងសង់ អគារព្យាបាលជំងឺទូទៅ ក្នុងមន្ទីរពេទ្យបង្អែកពារាំង ក្នុងខេត្តព្រៃវែង។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយ ឯកឧត្តម លោក ម៉ាសាហ៊្វុមិ គូរ៉ូគី ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក គ្រៀល រឿង ប្រធានការិយាល័យស្រុកប្រតិបត្តិពារាំង នៅស្ថានទូតជប៉ុន។

ដើម្បីឆ្លើយតបទៅនឹងកង្វះគ្រែសម្រាប់អ្នកជំងឺដែលត្រូវសម្រាកនៅមន្ទីរពេទ្យ ស្រុកប្រតិបត្តិពារាំង នឹងសាងសង់អគារពិនិត្យព្យាបាលជំងឺទូទៅមួយខ្នងដែលមានកម្ពស់២ជាន់ ក្នុងមន្ទីរពេទ្យបង្អែកពារាំង ខេត្តព្រៃវែង។ គម្រោងនេះនឹងធ្វើឲប្រជាជនប្រមាណ ២០០,០០០ នាក់ដែលរស់នៅក្នុងស្រុកពារាំង និង តំបន់ផ្សេងទៀតនៃខេត្តព្រៃវែង អាចមានភាពងាយស្រួលក្នុងការទៅមន្ទីរពេទ្យ និង ទទួលសេវាព្យាបាលជំងឺដ៏ប្រសើរពីបុគ្គលិកសុខាភិបាល។

កម្មវិធីគម្រោងជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណេ*) របស់រដ្ឋាភិបាលជប៉ុនដែលបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រកិច្ចខំប្រឹងប្រែង ដើម្បីជួយដល់ការអភិវឌ្ឍន៍ និង ស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះ ពីកត្តាមួយចំនួនដូចជាភាពក្រីក្រ និង ភាពអកុសល ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅការចិញ្ចឹមជិវិតនិងសេចក្តីថ្លៃថ្នូររបស់ពួកគេក៏ដូចជាជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៤៧លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងចំនួន៤៦០ នៅទូទាំងប្រទេស។

---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@pp.mofa.go.jp គេហទំព័រ: http://www.kh.emb-japan.go.jp*